ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៩ លេខ ១០

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



Work Activities

ប្រចាំខែតុលា ឆ្នាំ២០១៦



# មាតិកា


| ល.រ បរិយាយ | លេខទំព័រ |
|---|---|
| I- កិច្ចប្រជុំជំនាញបច្ចេកទេស | |
| - សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត និងការដាក់ឲ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេសពហុកីឡាដ្ឋានជាតិ | ១ |
| II- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត(ក្រុម RIA) | |
| ១- ដំណើរសិក្សាស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត | ២-៣ |
| ២- សិក្ខាសាលាស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត | ៤-៦ |
| III- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១៦ | ៧-១៥ |
| IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៦ | ១៦-១៩ |

# សេចក្តីព្រាងអនុក្រឹត្យស្តីពី

## ការបង្កើត និងការដាក់ឲ្យដំណើរការ ទីភ្នាក់ងារប្រតិបត្តិការពិសេសពហុកីឡាដ្ឋានជាតិ

កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អួន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តមសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត និងការដាក់ឲ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេសពហុកីឡាដ្ឋានជាតិ** ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងអប់រំ យុវជន និងកីឡា។

ឆ្លើយតបទៅនឹងការធ្វើកំណែទម្រង់ក្នុងវិស័យអប់រំ ការត្រៀមខ្លួនធ្វើជាម្ចាស់ផ្ទះ រៀបចំកីឡាស៊ីហ្គេម នៅឆ្នាំ២០២៣ និងផ្តល់សេវាហ្វឹកហាត់ដល់គ្រូបង្វឹកកីឡាករ កីឡា ការីនីជម្រើសជាតិ និងប្រជាពលរដ្ឋហាត់ប្រាណលេងកីឡាដើម្បីសុខភាពបានសមស្រប ក្រសួងអប់រំ យុវជន និងកីឡា បាន រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត និងការដាក់ឲ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេសពហុកីឡាដ្ឋានជាតិ សំដៅពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការផ្តល់សេវាលើកកម្ពស់សន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងផ្តល់សេវាសាធារណៈតាមតម្រូវការនៅក្នុងពហុកីឡាដ្ឋាន និងមានវិសាលភាពគ្របដណ្តប់លើការងារគ្រប់គ្រងថែទាំ និងផ្តល់សេវានៅក្នុងពហុកីឡាដ្ឋានជាតិ។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត និងការដាក់ឲ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេសពហុកីឡាដ្ឋានជាតិត្រូវបានរៀបចំឡើងដោយបានពិគ្រោះយោបល់ក្នុងកម្រិតថ្នាក់ដឹកនាំក្រសួងតាំងពីឆ្នាំ២០១៤ និងបានដាក់ឆ្លងកិច្ចប្រជុំបច្ចេកទេសនៃទីស្តីការគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥។ ក្រោយពីបានកែសម្រួលតាមស្មារតីកិច្ចប្រជុំរួចមក ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា បានឯកភាពបញ្ជូនសេចក្តីព្រាងកែសម្រួលថ្មីនេះមកទីស្តីការគណៈរដ្ឋមន្ត្រីតាមនីតិវិធីម្តងទៀត[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត និងការដាក់ឲ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេសពហុកីឡាដ្ឋានជាតិ។

# ១- ដំណើរសិក្សាស្ដីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

### ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍ លេខ៨៨៣៤
### នៅសណ្ឋាគារសុខាអង្គរ ខេត្តសៀមរាប ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦

នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្ដីការគណៈរដ្ឋមន្ត្រី បានសហការជាមួយ ធនាគារអភិវឌ្ឍន៍អាស៊ី រៀបចំនូវដំណើរសិក្សាស្ដីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដឹកនាំដោយ ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ ដែលមានអ្នកចូលរួមចំនួន ១០៥នាក់ មកពី ១៤ក្រសួង: ក្រសួងពាណិជ្ជកម្ម ក្រសួងរ៉ែ និងថាមពល ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងសុខាភិបាល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងគ្រប់គ្រងដែនដីនគរូបនីយកម្មនិងសំណង់ និងក្រសួងយុត្តិធម៌។



ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (រូបកណ្ដាល)

វិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត Regulatory Impact Assessment ហៅកាត់ថា RIA គឺជាវិធីសាស្ត្រសម្រាប់វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដែលជាទម្លាប់អនុវត្តល្អសម្រាប់ដំណើរការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត ដែលផ្ដល់ផលចំណេញច្រើន ហើយក៏មានប្រទេសអភិវឌ្ឍជាច្រើនជាសមាជិក OECD ទទួលស្គាល់យ៉ាងទូលំទូលាយអស់រយៈជាច្រើនទសវត្សមកហើយ និងប្រទេស ASEAN រួមមាន វៀតណាម ឡាវ ថៃ ហ្វីលីពិន និងម៉ាឡេស៊ីជាដើម ក៏ទទួលស្គាល់នូវអត្ថប្រយោជន៍នោះដែរ ដូចជា៖

- លិខិតបទដ្ឋានមានគុណភាពខ្ពស់ នាំឲ្យអភិបាលកិច្ចល្អ និងការអភិវឌ្ឍសេដ្ឋកិច្ច
- ថ្នាក់ដឹកនាំអាចធ្វើការសម្រេចបញ្ញត្តិកម្មសមរម្យ ដោយផ្អែកលើទិន្នន័យដែលសំអាងលើពិសោធ៍



- បង្កើនតម្លាភាព និងកសាងជំនឿទុកចិត្តដល់សាធារណៈជន ដោយសារមានគោលការណ៍ណែនាំច្បាស់លាស់សម្រាប់កិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ

- ជួយកាត់បន្ថយបន្ទុកចំណាយរបស់រដ្ឋាភិបាល។

កម្មវិធីRIAនេះ គឺជាផ្នែកមួយនៃការខិតខំរបស់រាជរដ្ឋាភិបាល ក្នុងការកំណែទម្រង់លើគ្រប់វិស័យ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា សំដៅធ្វើឲ្យសម្រេចបាននូវសន្តិសុខសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។

នៅឆ្នាំ២០១៧ខាងមុខ កម្មវិធីRIA គ្រោងនឹងបន្ថែមក្រសួងប្រមាណ៦ទៀតដើម្បីចូលរួមវគ្គបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឲ្យកាន់តែមានទម្លាប់ល្អក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត នៅព្រះរាជាណាចក្រកម្ពុជា៕



# ២- សិក្ខាសាលាស្តីពីការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត

### នៅសណ្ឋាគារសុខាភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦

នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម សហការជាមួយក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី (ក្រុមRIA) បានរៀបចំសិក្ខាសាលាស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តក្រោមជំនួយបច្ចេកទេសរបស់ADBលេខ៨៨៣៤។

សិក្ខាសាលានេះដឹកនាំដោយសហប្រធានគឺ ឯកឧត្តម **ហេង សុខគង់** រដ្ឋលេខាធិការ តំណាងឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ហើយមានអ្នកចូលរួមប្រមាណ ២២០នាក់ (ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម មន្ត្រីកម្មវិធីRIA មកពីECOSOCC, MoC, MME, MoE, MoT, MEYS, MLVT, MAFF, MPWT, MOH, PMTC, MEF, PLMUC ផ្នែកឯកជន ដៃគូរអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល។




ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

វាគ្មិននៅក្នុងព្រឹត្តិការណ៍ថ្ងៃនេះ រួមមានឯកឧត្តម **ម៉ិច សុខា** អគ្គលេខាធិការរងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ Mr. Rabin Hattari តំណាងធនាគារអភិវឌ្ឍន៍អាស៊ី លោក **ចាតសូ សុភ័ក្រ** អគ្គនាយករងក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA) គឺជាទម្លាប់អនុវត្តល្អសម្រាប់ដំណើរការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត ដែលផ្តល់ផលចំណេញច្រើន ហើយមានប្រទេសអភិវឌ្ឍជាច្រើនដែលជាសមាជិកនៃ OECD (អង្គការអភិវឌ្ឍសេដ្ឋកិច្ច និងសហប្រតិបត្តិការ) និងម្យ៉ាងទៀតនៅប្រទេស ASEAN ដូចជាវៀតណាម ឡាវ ថៃ ហ្វីលីពីន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ទទួលស្គាល់យ៉ាងទូលំ




ទូលាយថា៖

- លិខិតបទដ្ឋានមានគុណភាពខ្ពស់ ដែលមានអភិបាលកិច្ចល្អ និង ការអភិវឌ្ឍសេដ្ឋកិច្ច;
- អ្នកធ្វើសេចក្តីសម្រេចអាចធ្វើការសម្រេចបញ្ញត្តិកម្មប្រកបទៅដោយទិន្នន័យផ្អែកលើការអនុវត្តជាក់ស្តែង;
- បង្កើនតម្លាភាព និងកសាងជំនឿទុកចិត្តដល់សាធារណៈជន ដោយសារមានគោលការណ៍ណែនាំច្បាស់លាស់សម្រាប់កិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ;
- ជួយកាត់បន្ថយបន្ទុកចំណាយរបស់រាជរដ្ឋាភិបាលលើការអនុវត្ត និងបន្ទុកចំណាយប្រតិបត្តិការរបស់ធុរកិច្ច






អភិបាលកិច្ចល្អ គឺជាចំណុចកណ្តាលនៃរបៀបវារៈរបស់រាជរដ្ឋាភិបាលដែលបានកំណត់នៅក្នុងយុទ្ធសាស្រ្តចតុកោណ។ ដំណើរការ RIA នឹងកាត់បន្ថយការិយាធិបតេយ្យ និង ភាពច្រើនហួស/ភាពជាន់គ្នានៃលិខិតបទដ្ឋានគតិយុត្ត។

បច្ចុប្បន្នECOSOCC មានតួនាទីជាអ្នកបណ្តុះបណ្តាលដល់ក្រសួងអនុវត្តRIAចំនួន១៣ គឺក្រសួងពាណិជ្ជកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងសុខាភិបាល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងសាធារណៈការនិងដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់។

នៅដើមឆ្នាំ២០១៧ គ្រោងនឹងបន្ថែមក្រសួងចំនួន៦ទៀត។ ដូច្នេះទៅថ្ងៃមុខ ក្រសួងសំខាន់ៗទាំង១៩ នឹងបានយល់ដឹងអំពីRIAនិងអត្ថប្រយោជន៍របស់RIA និងអាចមានធនធានមនុស្សអនុវត្តRIAបាន។

ECOSOCC បានរៀបចំសេចក្តីព្រាងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើតក្រុមRIA នៅតាមក្រសួងនានា រួចរាល់ហើយ នឹងដាក់ជូនថ្នាក់ដឹកនាំ ដើម្បីពិនិត្យសម្រេច៕

## III- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១៦ *



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ **ប្រចាំខែកញ្ញា ឆ្នាំ២០១៦**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

### ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែកញ្ញាឆ្នាំ២០១៦សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៣% ធៀបនឹងខែមុន និងកើនឡើង៣,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ម្ហូបអាហារ: | +៥,៣% | សាច់ជ្រូក: | +៣,៨% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +១០,៣% | សាច់គោ: | +១០,៨% |
| សំលៀកបំពាក់ និងស្បែកជើង : | +៤,២% | សាច់មាន់: | +៦,៥% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់ : | +៤,៣% | ត្រីស្រស់: | +៩,១% |
| សុខាភិបាល : | +២,៥% | ផ្លែឈើ: | +៤,៤% |
| ការកម្សាន្ត និងវប្បធម៌ : | +៣,៧% | បន្លែ: | +៦,១% |
| ភោជនីយដ្ឋាន: | +២,១% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៤–២០១៦

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា P | វិច្ឆិកា P | ធ្នូ P | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ២,៩% | ៣,១% | ៣,៤% | ២,៩% |
| | មុន | - 0,២% | 0,៤% | -0,២% | ១,៤% | 0,៥% | 0,២% | 0,៣% | 0,២% | 0,៣% | -0,១% | 0 | 0,៥% | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | 0,៤% | ១,៦% | ១,១% | ១,៣% | ១,0% | 0,៧% | 0,៨% | 0,៨% | 0,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| | មុន | -0,៤% | ១,២% | 0,១% | 0,៧% | 0,១% | 0,២% | 0,៦% | 0,៣% | 0,២% | 0% | -0,២% | 0,២% | |
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,0% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ២,៥% | ៣,៩% |
| | មុន | 0,២% | 0 | 0,៥% | 0,៥% | 0,៣% | 0,៥% | 0,៤% | 0,៣% | 0,២% | -0,៤% | -0,៨% | 0,៧% | |

**P:** តួលេខខែ តុលា វិច្ឆិកា ធ្នូ និងឆ្នាំ២០១៦ ជាតួលេខព្យាករ (តាមវិធីសាស្រ្ត **DECOMPOSITION)**

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | កញ្ញា២០១៦ | សីហា២០១៦ | កញ្ញា២០១៥ | *ប្រភេទ* | កញ្ញា២០១៦ | សីហា២០១៦ | កញ្ញា២០១៥ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៨០៛/១$ | ៤០៩៦៛/១$ | ៤០៧៦៛/១$ | **បាត/ដុល្លារ** | ៣៤,៥៨បាត/១$ | ៣៤,៦០បាត/១$ | ៣៦,៤១បាត/១$ |
| **៛/បាត** | ១១៨៛/១បាត | ១១៨៛/១បាត | ១១២៛/១បាត | **ដុង/ដុល្លារ** | ២២២៩១ដុង/១$ | ២២២៧០ដុង/១$ | ២២៤៨៦ដុង/១$ |
| **៛/ដុង** | ០,១៨៣៛/១ដុង | ០,១៨៤៛/១ដុង | ០,១៨១៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែកញ្ញាឆ្នាំ ២០១៦ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១១២៧,០ប៊ីលានរៀល គិតជាដុល្លាអាមេរិកស្មើ**២៨១,៧** លានដុល្លា( *មធ្យមប្រចាំខែ ១០៥% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន ១១២១,៨ប៊ីលានរៀល( *មធ្យមប្រចាំខែ ១០៧% នៃផែនការ*) និងចំណូលមូលធនចំនួន៥,៣ប៊ីលានរៀល (តាមតួលេខ ធនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៤-២០១៦ (ប៊ីលានរៀល)




- ➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិកើនឡើង១,៧% ប៉ុន្តែ កើនឡើង២,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ➢នៅក្នុងចំណូលចរន្ត:
  - ✓ចំណូលសារពើពន្ធមានចំនួន ៩៣០,៣ប៊ីលានរៀល ថយចុះ០,៤%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង០,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខធនាគារជាតិ)។
  - ✓ចំណូលមិនមែនសារពើពន្ធ មានចំនួន១៩១,៥ប៊ីលានរៀល កើនឡើង១០,៣% ធៀបនឹងខែមុន និងកើនឡើង១២,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ ធនាគារជាតិ)។

តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

| ចំណូលសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: -៥,១% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+០,៧%) | ➢កាស៊ីណូ: +៥០១,៩% | (+៩៧៥,៦%) |
| | | ➢អាជ្ញាបណ្ណក្នុងស្រុក : -១៧,៦% | (-១៥,៨%) |
| ➢ *ចំណូលពន្ធដារ:* +៥,១% (អគ្គនាយកដ្ឋានពន្ធដារ) | (+១៦,១%) | ➢ នេសាទ:-៤៦,២% | (-៧១,៧%) |
| | | ➢សម្បទានរ៉ែ: +១៣១២,៤% | (+៣៥៨១,៧%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: -៨៦,៤% | (-៨៧,៨%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: -១០០% | (-១០០%) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ): -២៣% | (-៧,៧%) |

**២.២. ចំណាយថវិកាជាតិ :** អនុវត្តបាន ១២៦៧,៦ប៊ីលានរៀល គិតជាដុល្លាអាមេរិកស្មើ**៣១៦,៩** លានដុល្លា( *មធ្យមប្រចាំខែ ៧៩% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន១០២៥,៣ ប៊ីលានរៀល (*មធ្យមប្រចាំខែ ៨០% នៃផែនការ*) និងចំណាយមូលធនមានចំនួន២៤២,៣ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិកើនឡើង៣២,២%ធៀបនឹងខែមុននិងកើនឡើង១៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង២៨,៥%ធៀបនឹងខែមុននិងកើនឡើង៧,៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានឱនភាពចំនួន **១៤០,៦** ប៊ីលានរៀល គិតជាដុល្លាអាមេរិកស្មើ**៣៥,១៥** លានដុល្លា (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៤-២០១៦






## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកញ្ញាឆ្នាំ២០១៦មានលក្ខណៈដូចខាងក្រោម:

➢ រូបិយវត្ថុ **$M_2$** មានចំនួន៥៧១២៨ប៊ីលានរៀលកើនឡើង០,៦%ធៀបនឹងខែមុន និងកើនឡើង២១,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការកើនឡើង **$M_2$** ក្នុងខែនេះ ជារួម បណ្តាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ ៤,៦% និង ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ ៥,៤%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែកញ្ញាឆ្នាំ២០១៦




➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៦,៦% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,៤% នៃរូបិយវត្ថុ **$M_2$**។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៦

| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៦,៨% | ១៦,៦% | ១៥,៩% | ១៥,៨% | ១៥,៧% | ១៥,៩% | ១៥,៩% | ១៦% | ១៦,៦% | | | |
| ប្រាក់រៀលក្រៅធនាគារ | ១២,២% | ១២,១% | ១១,៩% | ១១,៦% | ១១,២% | ១១,៣% | ១១,២% | ១១,៣% | ១១,៨% | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែកញ្ញា២០១៦: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១៨៧៩៧ ប៊ីលានរៀល កើនឡើង ១,៤% ធៀបនឹងខែមុន និងកើនឡើង៣៧,០%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៦០៤០លានដុល្លារ កើនឡើង២,១%ធៀបនឹងខែមុន និងកើនឡើង២៩,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្តល់ដោយ | កញ្ញា២០១៦ | សីហា២០១៦ | កញ្ញា២០១៥ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) | ៥៥៩៩១ | ៥៥៦១៤ | ៤៤៣៤៦ |
| ក្នុងនោះ ជារៀល | | ៧៧៨ | ៥៦៧ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១១៦៥៧ | ១១៣០៤ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៧៨% | ៦,៨០% | ៦,៦២% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៧,៣៣% | ១៧,៣៣% | ១៦,២០% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤២% | ៤,៥០% | ៤,៤២% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៨៤% | ១១,៨៨% | ១១,៦២% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថកសិករ | | ៣១,២% | ៣១,២% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | | ២៨,៨% | ៣០% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | | ២២,៨% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែកញ្ញាឆ្នាំ២០១៦ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៧០,៤ពាន់តោនថយចុះ៧%ធៀបនឹងខែមុនប៉ុន្តែកើនឡើង១១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៥៧៩,០៣GWHមានការថយចុះ២%ធៀបនឹងខែមុន និងកើនឡើង១៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន៤៣៧,៥៣GWH មានការថយចុះ១%ធៀបនឹងខែមុន និងកើនឡើង១៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន៨៤,៣២GWHមានការកើនឡើង១%ធៀបនឹងខែមុន និងកើនឡើង៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៦៤១,៣លានដុល្លារមានការថយចុះ៣%ធៀបនឹងខែមុន និងកើនឡើង២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –កញ្ញា២០១៦ | ចំនួន–សីហា២០១៦ | ចំនួន–កញ្ញា២០១៥ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១៤ | ១៣ | ២៧ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៥៥៤ | ១៥៤៣ | ១៤២៦ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | | | ៤០ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | | | ៣៤ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន៨៣៦,៨ ពាន់ម$^{២}$កើនឡើង១៩៤%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៣៤១,៨លានដុល្លារកើនឡើង២១២%ធៀបនឹងខែមុន និងកើនឡើង៧%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម² –កញ្ញា២០១៦ | ពាន់ម² –សីហា២០១៦ | ពាន់ម² –កញ្ញា២០១៥ |
|---|---|---|---|
| ▪ លំនៅឋាន | ៥៣០,៥ | ១៣១,៨ | ៦៣៣,៣ |
| ▪ ឧស្សាហកម្ម | ២៧៧,៤ | ៤៣,៧ | ៩៣,៣ |
| ▪ពាណិជ្ជកម្ម | ១៥,៥ | ១៥,៣ | ៤,២ |
| ▪ ទេសចរណ៍ | ១២,២ | ៩០,៦ | ២៧,៦ |
| ▪ផ្សេងៗ | ១,២ | ៣,០ | ៣,២ |
| អនុញ្ញាតសរុប | ៨៣៦,៨ | ២៨៤,៦ | ៧៦៦,១ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅដ្ឋាន៦៣,៤% និងឧស្សាហកម្ម៣៣% នៃផ្ទៃក្រឡាសរុប។

➢**ការងារ**

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–កញ្ញា២០១៦ | នាក់–សីហា២០១៦ | នាក់–កញ្ញា២០១៥ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ ) | ១៥៥៩ | ១៥៧៣ | ៦៥៣ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៩២៧១ | ១២៦៥៣ | ៩៦៧២ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៦៨៨២ | ១១៧២១ | ៨០៩៦ |
| អ្នកទទួលបានការងារក្រៅប្រទេស | ២៣៨៩ | ៩៣២ | ១២៤១ |

➢**វិនិយោគ**

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | កញ្ញា២០១៦ | សីហា២០១៦ | កញ្ញា២០១៥ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ១០៧,២ | ៣០,៤ | ៤៧០,៨ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៣៥,៣ | ០ | ០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៥១,៩<br>៤,៥ | ២៥,៤<br>(០,៦) | ៤១,៥<br>(៣,០) |
| វិស័យទេសចរណ៍ | ០ | ០ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ២០ | ៥,១ | ៤២៩,៣ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១២ | ៩ | ១១ |
| បង្កើតការងារ (ពាន់នាក់) | ១៣,៨ | ៥,៨ | ១២,២ |

### ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន—កញ្ញា២០១៦ | ចំនួន—សីហា២០១៦ | ចំនួន—កញ្ញា២០១៥ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៣៦៨ | ៣៥៤ | ៣៥២ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ០ | ០ | ១ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | ៣៩៥ | ២០៥ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៦៣៣ពាន់តោនថយចុះ៣%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៦%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងរង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:-២៦% | (+៣%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:-៩% | (-៣៨%) |
| ▪ កំពង់ផែកំពង់សោម:+១៣% | (+៣០%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +៨% | (-៥២%) |

### ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៣,៦ | -១១% | ៥% |
| ក្នុងនោះទទួល | ២,៤ | ០% | ៦% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៧៩,៧ | -១៩% | -៤% |
| ក្នុងនោះទទួល | ៤៣ | -៩% | ៣% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២៦៣៥,៥ | -១១% | -១៩% |
| ក្នុងនោះហៅចូល | ៨០៧,៩ | -១១% | -១៤% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៩១៨៤,៩ | -៨% | -២៧% |
| ក្នុងនោះហៅចូល | ៩១១៥,៤ | -៨% | -២៧% |

### ➢ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១០ | -២៩% | ៥៣% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២៦,៧ | -១៩% | -៧% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៤៤១,៥ | -១៣% | ១៦% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១២១,៩ | -០.៥% | ១៥% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៣៤៥,៥ | -១៥% | ១០% |
| ✓ តាមផ្លូវអាកាស | ១៨២,៦ | -១១% | ១០% |
| ✓ តាមផ្លូវគោក និងទឹក | ១៦២,៦ | -១៩% | ៩% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែកញ្ញាមានចំនួន ៤១៧៨,៥ប៊ីលានរៀល (ស្មើនឹង ១០៤៤,៦លានដុល្លារ ស.រ.អា.)ថយចុះ៣,៥%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ :

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -២,៩% | -៩,១% | រថយន្តសរុប (ប៊ី.ល.រ) | -៣,៩% | -១៨% |
| ប្រេងម៉ាស៊ូត | +៣,៨% | +១៦,១% | រថយន្តសរុប (គ្រឿង) | -១០,៧% | -១១,៩% |
| ឧស្ម័ន | -៥,២% | -០,៩% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +១៣,៥% | -៤២,៤% |
| អគ្គិសនីនាំចូល | -១១,០% | +៨,០% | ម៉ូតូ (គ្រឿង) | -២៧,៦% | +១៣,៣% |
| ដែកសំណង់ | +៣,២% | -៦៦,៧% | អង្ករ | -៤៩,៧% | -៨៧,៥% |
| ស៊ីម៉ង់ត៍ | -១៧,៨% | -២៨,៤% | ផ្លែឈើនិងបន្លែ | -១៥,៨% | -១១,៩% |
| គ្រឿងអេឡិចត្រូនិក | | | ជីនិងថ្នាំកសិកម្ម | +១០,២% | +១៤,៨% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិ | -៨,៣% | -៧,៥% |

➡ **ការនាំចេញ** ខែកញ្ញាឆ្នាំ២០១៦ មានចំនួន ៣៥៧៤ប៊ីលានរៀល ស្មើនឹង**៨៩៣,៥**លានដុល្លារ ស.រ.អា. (**៨៨,៦**% នៃការនាំចូល)ថយចុះ៦,៩%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៤,៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +៣៣,១% | -១៣,១% | ផលិតផលនេសាទ | +១១៧,៩% | +១៦៤,៧% |
| វាយនភណ្ឌនិងស្បែកជើង | -៥,២% | +១៨,១% | កៅស៊ូ | +១០,៦% | +២៧,៦% |
| អង្ករ | +៨៨% | +៣៧,០% | | | |

➡ក្នុងខែកញ្ញានេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៦០៤,៥ប៊ីលានរៀលស្មើនឹង១៥១,១២លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកញ្ញាឆ្នាំ២០១៦នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃសាច់គោស្រស់ | +០,៣% | +១០,៨% | |
| ២ | ថ្លៃត្រីស្រស់ | +១,២% | +៩,១% | — |
| ៣ | ថ្លៃបន្លែ | +០,៨% | +៦,១% | |
| ៤ | ទុនវិនិយោគអនុញ្ញាតដោយ ក.អ.ក . (គ.វ.ក និង គ.ស.ព.) | +២៥២,១% | -៧៧,២% | |
| ៥ | ការនាំចេញអង្ករ | +៨៨% | +៣៧% | |

## ៧) សេចក្តីសន្និដ្ឋាន

១) អង្គប្រជុំបានពត៌មានថា ម្ហូបអាហារដូចជា សាច់ ត្រី បន្លែ ផ្លែឈើ ទឹកត្រី ទឹកស៊ីអ៊ីវ និងផលិតផលកែច្នៃដទៃទៀតក្នុងបរិមាណរាប់សិបតោន បានឆ្លងដែនពីវៀតណាមមកកម្ពុជាជារៀងរាល់ថ្ងៃ ដោយគ្មានការពិនិត្យសារធាតុគីមីហាមឃាត់ និងសារធាតុពុលដទៃទៀតដែលប្រើសម្លាប់សត្វល្អិតជាដើម បង្កឲ្យមានជំងឺគ្រោះថ្នាក់ជាច្រើនដូចជាមហារីក បេះដូង ក្រពះ ពោះវៀន។ល។ ការប្រើប្រាស់សារធាតុគីមីក្នុងផលិតកម្មគឺដើម្បីបង្កើនទិន្នផល និងបន្ទាបថ្លៃដើម។ ដោយសារតែទំនិញមកពីវៀតណាម មានថ្លៃទាបបើធៀបទៅនឹងផលិតផលកម្ពុជា ដូច្នេះការនាំចូលពីវៀតណាមមានការទាក់ទាញយ៉ាងខ្លាំងទោះគ្រប់គ្នាដឹងថា ជាផលិតផលគ្រោះថ្នាក់ក៏ដោយ។ អង្គប្រជុំក៏បានពត៌មានមួយទៀតថា សុវត្ថិភាពម្ហូបអាហារជាបញ្ហាចម្បងនៅវៀតណាម ហើយអាជ្ញាធរវៀតណាមក៏បានប្រកាសឲ្យប្រជាពលរដ្ឋរបស់ខ្លួនមានការប្រុងប្រយ័ត្ននឹងការប្រើប្រាស់ម្ហូបអាហារ និងព្រមានចំពោះការប្រើប្រាស់សារធាតុគីមីក្នុងផលិតកម្ម។
គួរពិនិត្យលទ្ធភាពរិតបន្តឹងតាមច្រកព្រំដែននូវការចូលផលិតផលដែលមានផ្ទុកសារធាតុគីមី ដោយយកបទដ្ឋានគតិយុត្តស្តីពីសុវត្ថិភាពម្ហូបអាហារជាមូលដ្ឋាន។

២) តម្រូវការលើផលិតផលកសិកម្មសរីរាង្គពិតជាមានការកើនឡើងខ្ពស់ជាសាកល ដូច្នេះកម្ពុជាគួរងាកទៅរកការដាំដុះបែបសរីរាង្គឲ្យបានទាន់ពេល ខណៈពេលដែលទីផ្សារនេះមិនទាន់មានការប្រកួតប្រជែងខ្លាំងក្លានៅឡើយ។ ដូច្នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរបំផុសចលនាកសិកម្មសរីរាង្គ គាំទ្រផ្នែកបច្ចេកទេស និងជំរុញការបង្កើតច្បាប់ស្តីពី កសិកម្មសរីរាង្គ៕

## IV- សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៦

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៣/១០/១៦<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់និស្សិត សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ២ | ០៤/១០/១៦<br>ម៉ោង០៩:០០នាទី | បន្តដឹកនាំកិច្ចប្រជុំ និងពិភាក្សាលើកទី១០ លើស្ថានភាពអត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលធ្វើបទបង្ហាញដោយ ឯកឧត្តម **ឱន វីរៈ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៥/១០/១៦<br>ម៉ោង០៩:០០នាទី | បន្តដឹកនាំកិច្ចប្រជុំ និងពិភាក្សាលើកទី១១ លើស្ថានភាពអត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលធ្វើបទបង្ហាញដោយ ឯកឧត្តម **ឱន វីរៈ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៦/១០/១៦<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិត សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៥ | ០៧/១០/១៦<br>ម៉ោង០៩:០០នាទី | បន្តដឹកនាំកិច្ចប្រជុំ និងពិភាក្សាលើកទី១២ លើស្ថានភាពអត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលធ្វើបទបង្ហាញដោយ ឯកឧត្តម **ឱន វីរៈ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១០/១០/១៦<br>ម៉ោង០៨:០០នាទី | តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងសន្និសីទក្រោមប្រធានបទ “ស្មារតីនៃសុន្ទរកថាទីក្រុងភ្នំពេញ និងប្រទេសកម្ពុជា” នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ |
| ៧ | ១០/១០/១៦<br>ម៉ោង១៥:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីតាំងពិព័រណ៍រូបថតស្តីពីដំណើរទស្សនកិច្ចនៅកម្ពុជារបស់ឧត្តមសេនីយ៍ Charles de Gaulle នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | **១១/១០/១៦ ម៉ោង០៨:០០នាទី** | តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីគារវកិច្ចតាំងពិព័រណ៍ឯកសារសំដែងរបាំព្រះរាជទ្រព្យ និងបញ្ចាំងខ្សែភាពយន្តឯកសារថ្វាយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅសាលសន្និសីទចតុមុខ។ |
| ៩ | **១១/១០/១៦ ម៉ោង១៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីរាត្រីសមោសរ ដែលរៀបចំឡើងរួមគ្នាជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សភាពាណិជ្ជកម្ម និងឧស្សាហកម្មបារាំង-កម្ពុជា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។ |
| ១០ | **១២/១០/១៦ ម៉ោង០៩:០០នាទី** | ចូលរួមជួបពិភាក្សាការងារជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅគេហដ្ឋានឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី។ |
| ១១ | **១២/១០/១៦ ម៉ោង១៥:០០នាទី** | បន្តដឹកនាំកិច្ចប្រជុំ និងពិភាក្សាលើកទី១៣ លើស្ថានភាពអត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលធ្វើបទបង្ហាញដោយ ឯកឧត្តម **ឌិន ធីរៈ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | **១៣/១០/១៦ ម៉ោង០៩:០០នាទី** | បន្តដឹកនាំកិច្ចប្រជុំ និងពិភាក្សាលើកទី១៤ លើស្ថានភាពអត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលធ្វើបទបង្ហាញដោយ ឯកឧត្តម **ឌិន ធីរៈ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | **១៣/១០/១៦ ម៉ោង១៥:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ឃឹម ណុលសន** ឯកឧត្តម **ខ៉ាន់ តិរុណា** និងឯកឧត្តម **ម៉ក់ ឆារ៉ា** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **១៤/១០/១៦ ម៉ោង១៥:០០នាទី** | ដឹកនាំកិច្ចប្រជុំ និងពិភាក្សាលើកចុងក្រោយ លើស្ថានភាពអត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលធ្វើបទបង្ហាញដោយ ឯកឧត្តម **ឌិន ធីរៈ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៥ | ១៥/១០/១៦<br>ម៉ោង០៧:០០នាទី | តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីគោរពវិញ្ញាណក្ខ័ន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" គំរប់ខួប ០៤ឆ្នាំ នៅសួនច្បារខាងកើតវិមានឯករាជ្យ និងនៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ១៥/១០/១៦<br>ម៉ោង០៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យទេសចរណ៍រវាងក្រសួងទេសចរណ៍កម្ពុជា និងក្រុមហ៊ុន **SHANGHAI SPRING INTERNATIONAL TRAVEL SERVICE (GROUP) CO.,Ltd** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | ១៩/១០/១៦<br>ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវាយតម្លៃស្នាដៃមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានដែលត្រូវទទួលគ្រឿងឥស្សរិយយសសម្រាប់ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | ២០/១០/១៦<br>ម៉ោង០៩:០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើះ<br>១-សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។<br>២-សេចក្តីព្រាងច្បាប់<br>ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។<br>៣-សេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | ២០/១០/១៦<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំព្រែកប្បាស ស្រុកព្រែកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២០ | ២០/១០/១៦<br>ម៉ោង១៧:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក **Eric DELOBEL CEO** ក្រុមហ៊ុន **SCA** នៅបន្ទប់ឯកឧត្តមប្រធាន **(ECOSOCC)** នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ២១ | **២១/១០/១៦ ម៉ោង០៨:៤៥នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។<br>២-សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។<br>៣-សេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។<br>៤-បញ្ហាផ្សេងៗ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២២ | **២១/១០/១៦ ម៉ោង១៥:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយ លោក **លី ស្មី** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៣ | **២៣/១០/១៦ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាគណៈអភិបាលរាជធានី ខណ្ឌ សង្កាត់ មន្ត្រីរាជការ បុគ្គលិក និងកងកម្លាំង នៃរដ្ឋបាលរាជធានីភ្នំពេញ ចំនួន ៣.៧៥៨នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ២៤ | **២៦/១០/១៦ ម៉ោង១៦:០០នាទី** | ចូលរួមជាអធិបតី ក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសមេដាយចំនួន ៤គ្រឿង ជូនថ្នាក់ដឹកនាំ និងវេជ្ជបណ្ឌិតជប៉ុន នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២៥ | **២៧/១០/១៦ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែកញ្ញា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៦ | **២៨/១០/១៦ ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៧ | **២៨/១០/១៦ ម៉ោង១៦:៣០នាទី** | ចូលរួមជាកិត្តិយសក្នុង ពិធីបើកការប្រកួតកីឡាជាតិលើកទី "1st National Games" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅពហុកីឡាដ្ឋានជាតិអូឡាំពិក។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in